# សេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាល ស្តីពីការដាក់បញ្ចូលពិការភាពនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិធ្វើបច្ចុប្បន្នកម្ម (ផយអជ) លើវិស័យពិការភាព~ ខេមរក្កដា ឆ្នាំ ២០០៩

## ១~ប្រធានបទៈ "ពិការភាព និងការអភិវឌ្ឍ"

## ២-សេចក្តីផ្តើម

នៅក្នុងប្រទេសកម្ពុជា ជនពិការដែលតាមការប៉ាន់ស្មានថាមានប្រហែលជា ៤%[១] (CSES 2004) នៃចំនួនប្រជាជនសរុប គឺស្ថិតនៅក្នុងចំនោមជនងាយរងគ្រោះបំផុត។ យោងតាមការស្ទង់មតិរបស់វិទ្យាស្ថានស្ថិតិជាតិបង្ហាញថា ប្រាក់ចំណូលរបស់ពួកគេនៅឆ្នាំ២០០៤ មានត្រឹមតែពាក់កណ្តាលនៃជនមិនពិការតែប៉ុណ្ណោះ។ ពិការភាព និងភាពខ្សោយ គឺជាកត្តាគ្រោះថ្នាក់ខ្លាំងបំផុត ដែលជាឧបសគ្គក្នុងការទទួលបាននូវការអប់រំថ្នាក់បឋមសិក្សា។ កុមារពិការ មានគំលាតទ្វេដង គឺពាក់ព័ន្ធនឹងភេទ និងទីតាំងតាមទីជនបទ (Filmer, WB 2005)។ ទោះបីជាមានសេចក្តីប្រកាស មិនយកកម្រៃសេវាថៃទាំសុខភាពក៏ដោយ មានតែ៨%នៃជនពិការប៉ុណ្ណោះ ដែលបានទទួលនូវសេវានេះ (ADD 2007)។

បណ្តាលអ្នកពាក់ព័ន្ធក្នុងវិស័យពិការភាពទាំងអស់ក្នុងប្រទេសកម្ពុជា យកលំនាំតាមនិយមន័យ ដែលកំណត់តាមការបែងចែកមុខងារអន្តរជាតិរបស់អង្គការសុខភាពពិភពលោក (WHO) ពិការភាព និងសុខាភិបាល (ICF) ឆ្នាំ២០០១ និងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការឆ្នាំ២០០៦ (UNCRPD)។ វាបានកំណត់ថា ជនពិការរួមបញ្ចូលអ្នកដែលមានភាពអន់ខ្សោយរយៈពេលយូរ ផ្នែកកាយសម្បទាផ្លូវចិត្ត ប្រាជ្ញា ឬវិញ្ញាណ ដែលនៅពេលជួបប្រទះឧបស័គ្គនានា អាចរារាំងពួកគេមិនឱ្យមានការចូលរួមយ៉ាងពេញលេញ និងមានប្រសិទ្ធិភាពក្នុងសង្គម ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ (UNCRPD )។

ព័ត៌មានទាំងនេះ បង្ហាញពីភាពក្រីក្រ របស់ជនពិការនៅក្នុងប្រទេសកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជា ដែលបានចុះហត្ថលេខាលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ (២០០៧) បានអនុម័តច្បាប់ស្តីពី "ការការពារ និងលើកកម្ពស់សិទ្ធិជនពិការ" ក្នុងឆ្នាំ២០០៩ ហើយទំនងជានឹងអនុម័ត "ផែនការសកម្មភាពជាតិសំរាប់ជនពិការ" ដោយរួមបញ្ចូលទាំង**ជនរងគ្រោះដោយសារគ្រាប់មីន និងសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម** (NPA-PWD) ផងដែរ។ ដំណើរការក្នុងការធ្វើវិសោធនកម្ម **ផយអជ**[២] គឺជាឱកាសតែមួយគត់ដើម្បីកាត់បន្ថយភាពក្រីក្រក្នុងចំណោមប្រជាជន ហើយដែលស្របតាមច្បាប់ និងផែនការថ្មី។

---

[១] ធនាគារអភិវឌ្ឍន៍អាស៊ី ប៉ាន់ស្មាន ខ្ពស់ជាងចំនួនរហូតដល់ ១៥% "កំណត់បញ្ហាពិការភាពទាក់ទងនឹងកាត់បន្ថយភាពក្រីក្រ : សិក្សាពីប្រទេសកម្ពុជា ១៩៩៩"

[២] ផយអជ : ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

ពិការភាពគឺជាមូលហេតុ និងផលវិបាកនៃភាពក្រីក្រ។ ចំពោះ **ផយអជ** ដែលបានធ្វើវិសោធនកម្ម ដែលតម្រូវឱ្យមានប្រសិទ្ធិភាពក្នុងការអនុវត្តន៍ចំពោះប្រជាជនក្រីក្រទូទៅ រាជរដ្ឋាភិបាលកម្ពុជា និងដៃគូរអភិវឌ្ឍន៍ ត្រូវបានលើកទឹកចិត្តក្នុងការដាក់បញ្ហាពិការភាព នៅក្នុងទីតាំងមួយដ៏លិចធ្លោរជាងមុន។

ដើម្បីបង្ហាញពីទស្សនៈរួមនៅក្នុងសេចក្តីថ្លែងការណ៍ សិក្ខាសាលាពិគ្រោះយោបល់ស្តីពី **"ពិការភាព និងគោលនយោបាយអភិវឌ្ឍន៍"** ត្រូវបានរៀបចំធ្វើឡើង នៅខែសីហា ឆ្នាំ២០០៨ ដោយអង្គការជនពិការអន្តរជាតិបារាំង (HIF) និងក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC) ហើយការពិនិត្យមើលឡើងវិញនូវសេចក្តីថ្លែងការណ៍នេះ ដើម្បីប្រមូលព័ត៌មាន និងបញ្ហាសម្រាប់សេចក្តីសេចក្តីថ្លែងការណ៍ឆ្នាំ២០០៩ ក្នុងចំណោមអ្នកពាក់ព័ន្ធសំខាន់ៗ ត្រូវបានសម្របសម្រួលដោយអង្គការជនពិការកម្ពុជា (CDPO)។ អង្គការសំខាន់ៗសរុបចំនួន៣៧ ដែលក្នុងនោះមានអង្គការតំណាងឱ្យសំលេងជនពិការ អង្គការថ្នាក់ជាតិ និង**អន្តរជាតិ**[៣] ព្រមទាំង មជ្ឈមណ្ឌលជាតិនៃជនពិការ (NCDP) បានធ្វើការរួមគ្នា ដើម្បីបង្ហាញពីការព្រួយបារម្ភរបស់ខ្លួន កំណត់នូវសមិទ្ធិផលដែលសម្រេចបាន និងផ្តល់អនុសាសន៍ ដើម្បីធានាឱ្យបាននូវការចូលរួមស្មើភាពគ្នា និងការកាត់បន្ថយភាពក្រីក្រ នៅក្នុងវិស័យសំខាន់ៗមួយចំនួន ដូចជាវិស័យសុខាភិបាល វិស័យអប់រំ សកម្មភាពមីន វិស័យការងារ និងការរកប្រាក់ចំណូល សមធម៌យេនឌ័រ និងអភិបាលកិច្ច ក្នុងចន្លោះឆ្នាំ២០០៧-២០១០។ ជាងនេះទៀត ផែនការសកម្មភាពជាតិសំរាប់ជនពិការ ដែលទទួលបានការយល់ព្រម ដោយក្រសួងសង្គមកិច្ច និងអាជ្ញាធរគ្រប់គ្រងសកម្មភាពមីន (CMAA) និងត្រូវអនុម័ត នៅឆ្នាំ២០០៩ ផ្តល់នូវលទ្ធផលវាស់វែងមួយបែបទៀត ដែលព្រមព្រៀងថានឹងត្រូវសម្រេចឱ្យបាននៅត្រឹមឆ្នាំ២០១១។

ផ្អែកលើអនុសាសន៍ទាំងនេះ អង្គការជនពិការ និងអ្នកពាក់ព័ន្ធក្នុងវិស័យពិការភាពផ្សេងទៀត ជំរុញអ្នកពាក់ព័ន្ធទាំងអស់ ឱ្យខិតខំអស់ពីសមត្ថភាព នៅក្នុងរង្វង់ប៉ុន្មានឆ្នាំខាងមុខនេះក្នុងការធ្វើវិសោធនកម្ម ផយអជ (២០០៩-២០១៣) ដើម្បីដាក់បញ្ចូលពិការភាព ទៅក្នុងសកម្មភាពរបស់ពួកគេ និងដើម្បីត្រួតពិនិត្យពីវឌ្ឍនភាពនៃការកាត់បន្ថយភាពក្រីក្រក្នុងចំណោមជនពិការ ដើម្បីឈានទៅសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs) របស់កម្ពុជា។

## ៣- <u>សូចនាករតាមដានរួម (JMIs)/ត្រួតពិនិត្យពីភាពរីកចំរើនរបស់សកម្មភាពដែលត្រូវការ/ការវិភាគពីការអនុវត្ត</u>

ការមិនបានមើលឃើញបញ្ហាពិការភាពនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងអវត្តមានសូចនាករតាមដានរួម គឺជាឧបសគ្គចំបងសម្រាប់វិស័យពិការភាព ក្នុងការតាមដានពីភាពរីកចំរើន ថាតើយុទ្ធសាស្ត្រ និងសកម្មភាពទាំងឡាយបានផ្តល់ផលប្រយោជន៍ដល់ជនពិការដែរឬអត់។ ដូច្នេះ អង្គការដែលផ្តោតទៅលើពិការភាព ស្នើសុំឱ្យដាក់បញ្ចូលពិការភាពជាបញ្ហាពាក់ព័ន្ធគ្រប់វិស័យ និងសូចនាករតាមដានរួមទៅក្នុង **ផយអជ** ថ្មី ដោយយកលំនាំតាមបទពិសោធន៍ ជោគជ័យនៃការដាក់បញ្ចូលពិការភាព។ ជាងនេះទៀតសោត សិក្ខាសាលាពិគ្រោះយោបល់ដ៏មានសារៈសំខាន់ ប្រមូលបាននូវអនុសាសន៍ជាច្រើនសំរាប់វិស័យ សំខាន់ៗ ដែលយើងស្នើសុំឱ្យដាក់បញ្ចូលទៅក្នុង **ផយអជ** ថ្មី និងឯកសារត្រួតពិនិត្យសូចនាករតាមដានរួម។ អនុសាសន៍សំខាន់ៗ មានបង្ហាញពិស្តារនៅក្នុងចំនុចបញ្ហា (ពីបញ្ហា ក-ង) នៅក្នុងលំដាប់លេខរៀងទី៤នៃសេចក្តីថ្លែងការណ៍នេះ ហើយមានភ្ជាប់នៅក្នុងប្រអប់ជាក់លាក់បន្ថែមនៅចុងសេចក្តីថ្លែងការណ៍រួមនេះផងដែរ។

---

[៣] មានបន្ទាប់ទៀត ទាក់ទងទៅនឹងអង្គការធ្វើលើវិស័យពិការភាប

## ៤-បញ្ហាសំខាន់ៗដែលមិនមានក្នុងសូចនាករតាមដានរួម (JMIs) និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) និងអនុសាសសន៍សម្រាប់ ផយអជ ថ្មី (២០០៩-២០១៣)

ដោយប្រកាន់ខ្ជាប់នូវចក្ខុវិស័យយូរអង្វែងរបស់រាជរដ្ឋាភិបាល ដែលថា *"...សម្រេចឱ្យបានកម្ពុជាមួយ ដែលមានសាមគ្គីភាពសង្គម មានការអប់រំជឿនលឿន និងមានវប្បធម៌ភ្លឺថ្លា ដោយគ្មានភាពក្រីក្រ គ្មានអនក្ខរកម្ម និងគ្មានសុខភាពមិនល្អ សម្រាប់ប្រជាជនកម្ពុជាទាំងអស់រស់នៅជាមួយគ្នាក្នុងភាពសុខដុម ដោយរួចផុតពីភាពអត់ឃ្លាន វិសមភាព ការបោះបង់ចោល និងភាពងាយរងគ្រោះ (..) ហើយសម្រាប់ពលរដ្ឋទាំងអស់អាចសម្រេចបាននូវ សមត្ថភាពពេញលេញក្នុងវិជ្ជាជីវៈដែលពួកគាត់បានជ្រើសរើសដើម្បីរួមចំណែកក្នុងការធ្វើឱ្យប្រទេសជាតិមានវឌ្ឍនភាពជាបន្តទៅទៀត និងសម្រាប់ការកើនឡើងយ៉ាងខ្ពស់នៃកម្រិតរស់នៅ"* យើងខ្ញុំសូមដាក់ជូននូវបញ្ហា និងអនុសាសន៍ ទាក់ទង**ថាតើតាមរយៈការដាក់បញ្ចូលពិការភាពទៅក្នុងការត្រួតពិនិត្យ និងយុទ្ធសាស្ត្រ អាចធ្វើឱ្យ ផយអជ ថ្មី (២០០៩-២០១៣) និងសូចនាករតាមដានរួមរបស់ខ្លួន ជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋកម្ពុជាទាំងអស់តាមរបៀបណា។**

អនុសាសន៍ទាំងនេះ មានបំណងគាំទ្រដល់ការវិវត្ត ដ៏គួឱ្យស្ញប់ស្ញែង និងមានសារៈសំខាន់ផ្នែកនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា:

- បានអនុម័តច្បាប់ជនពិការ ខែឧសភា ឆ្នាំ២០០៩
- បានអនុម័តផែនការសកម្មភាពជាតិសំរាប់ជនពិការ ដោយរួមបញ្ចូលផងដែរទាំងអ្នកដែលនៅរស់រានមានជីវិតពីសំណល់ជាតិផ្ទុះ/គ្រាប់មីន ពីសង្គ្រាម ២០០៩- ២០១១ និង
- បានចុះហត្ថលេខាលើអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិជនពិការ ក្នុងខែតុលា ឆ្នាំ២០០៧

### (បញ្ហា ក) កាត់បន្ថយភាពក្រីក្រជាគោលការណ៍សំរាប់ផែនការ និងសកម្មភាពដ៏ទៃទៀត

ខណៈដែល**ជនពិការត្រូវបានគូសបញ្ជាក់នៅក្នុងជំពូកនៃ ផយអជ ស្តីពីយុទ្ធសាស្ត្រ និងសកម្មភាពសំខាន់ៗ** (ទំព័រ ៤៩) ថាជាក្រុមមួយក្នុងចំណោមអ្នកដែលខ្វះខាត និងទទួលបានសេវាតិចតួចជាងគេបំផុត "ដើម្បីជួយកាត់ បន្ថយភាពក្រីក្រឱ្យបានឆាប់រហ័ស" (ជំពូក៤ ចំណុច ៤.០៥) យើងកត់សំគាល់ឃើញថា **ជនពិការមិនត្រូវបានរៀបរាប់ បញ្ជាក់អោយបានជាក់លាក់ នៅក្នុងគោលដៅយុទ្ធសាស្ត្រទាំង១៥ និងចំនុចដៅសំខាន់ៗទាំង៤៣ នោះទេ។**

### (អនុសាសន៍ ក) ការដាក់បញ្ចូលពិការភាពទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិថ្មី —កាត់បន្ថយភាពក្រីក្រ

→ នៅក្នុងជំពូកនៃ **ផយអជ** ស្តីពី "វឌ្ឍនភាពដែលមានកន្លងមក និងស្ថានភាពបច្ចុប្បន្ន" រួមមានព័ត៌មានពិតស្តីពីពិការភាព ដូចដែលមានបង្ហាញក្នុងសេចក្តីថ្លែងការណ៍ចំនុច៤ និងប្រអប់ដែលនិយាយពីវិស័យជាក់លាក់ខាងក្រោម ចាប់ពីទំព័រទី៦ឡើងទៅ។

→ នៅក្នុង ផ.យ.អ.ជ សូចនាករសំខាន់ៗ គោលដៅ យុទ្ធសាស្ត្រ និងសកម្មភាពសំខាន់ៗ ដាក់បញ្ចូលជនពិការជាផ្នែកដែលពាក់ព័ន្ធលើគ្រប់វិស័យ និងជាក្រុមគោលដៅសម្រាប់ការងារកាត់បន្ថយភាពក្រីក្រ ដោយមានសន្ទស្សន៍វាស់វែងច្បាស់លាស់ ដែលយ៉ាងហោចណាស់មាននៅក្នុងវិស័យសំខាន់ៗមួយចំនួន ដូចជាសុខាភិបាល ការងារ ហេដ្ឋារចនាសម្ព័ន្ធ អភិបាលកិច្ច ប្រព័ន្ធសុវត្ថិភាពសង្គម យេនឌ័រ និងការអប់រំត្រឹមឆ្នាំ២០១០។

→ ក្រោមមុំទាំងបួននៃយុទ្ធសាស្ត្រចតុកោណ ផែនការ **ផយអជ នៅពេលអនាគត** ស្តីពី "ការកសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្ស" "ការស្តារលទ្ធភាពពលកម្ម និងការកសាងហេដ្ឋារចនាសម្ព័ន្ធ" "ការលើកស្ទួយវិស័យកសិកម្ម" និង "ការអភិវឌ្ឍវិស័យឯកជន និងការបង្កើតការងារ" រួមមានសកម្មភាពមួយចំនួន ដូចជាការកសាងសមត្ថភាពស្តីពីពិការភាព ច្បាប់ជនពិការ អនុសញ្ញាអង្គការសហប្រជាជាតិក្នុងរង្វង់រាជរដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់ និងក្នុងចំណោមដៃគូរអភិវឌ្ឍន៏ផ្សេងៗទៀត តាមរយៈការលើកកម្ពស់ចំណេះដឹង គោលការណ៍ណែនាំដែលគាំទ្រដោយរដ្ឋាភិបាលចំពោះការដាក់បញ្ចូលពិការភាព និងការផ្លាស់ប្តូរចំណេះដឹងត្រឹមឆ្នាំ២០១៣។

→ ជំរុញឱ្យមានការកែតម្រូវផ្នែកពិការភាពក្នុងវិស័យនីមួយៗនៃ **"យុទ្ធសាស្ត្រ និងសកម្មភាពសំខាន់ៗ"** និងការអនុវត្តគោលនយោបាយតាមវិស័យ ឬយុទ្ធសាស្ត្រ និងផែនការរបស់ក្រសួង សម្រាប់អភិបាលកិច្ច និងវិមជ្ឈការ ការអប់រំ សុខាភិបាល ប្រព័ន្ធសុវត្ថិភាពសង្គម និងការងារ

→ នៅក្នុងជំពូក "យុទ្ធសាស្ត្រ និងសកម្មភាពសំខាន់ៗ" ស្តីពីការជុំរុញឱ្យរាជរដ្ឋាភិបាលផ្តល់សច្ចាប័នដល់អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ ដែលបានចុះហត្ថលេខារួចហើយ ។

- o ធានាឱ្យបាននូវការដាក់បញ្ចូល និងការអនុវត្តពេញលេញនូវច្បាប់ស្តីពីការការពារ និងលើកកម្ពស់សិទ្ធិជនពិការ ដោយលើកកម្ពស់ និងត្រួតពិនិត្យផែនការជាតិគ្រប់វិស័យ ។

→ **តាមរយៈ** "យុទ្ធសាស្ត្រ និងសកម្មភាពសំខាន់ៗ" នៃផែនការ ផយអជ ជុំរុញឱ្យមានការផ្សព្វផ្សាយ និងអនុវត្តផែនការសកម្មភាពជាតិសម្រាប់ជនពិការ ដោយរួមបញ្ចូលទាំង ជនរងគ្រោះដោយសារគ្រាប់មីន និងសំណល់ជាតិផ្ទុះសល់ពីសង្គ្រាមនៅទូទាំងប្រទេស **ដែលជាផ្នែកមួយដ៏សំខាន់នៃមុំសំខាន់ៗ ដូចជាសុខាភិបាល វិមជ្ឈការ និងវិសហមជ្ឈការ ការអប់រំ ជំនួយជនរងគ្រោះដោយសារគ្រាប់មីន ការងារ និងអភិវឌ្ឍជនបទ**

→ នៅក្នុងផ្នែក "ត្រួតពិនិត្យ និងវាយតំលៃ" នៃផែនការ ផយអជៈ ដាក់បញ្ចូលពិការភាពទៅក្នុងវិទ្យាស្ថានស្ថិតិជាតិ នៃក្រសួងផែនការ និងការបង្ហាញទិន្នន័យដែលមាន ស្រាប់ស្តីពីពិការភាព និងភាពខ្សោយ ដែលជាផ្នែកមួយនៃការបោះពុម្ពផ្សាយការត្រួតពិនិត្យប្រចាំឆ្នាំ ដោយប៉ាន់ស្មាន ពីឥទ្ធពលនៃភាពខ្សោយ និងឧបសគ្គពីសង្គម/បរិស្ថាន ចំពោះការកាត់បន្ថយភាពក្រីក្រលើគ្រប់វិស័យ ដើម្បីឆ្ពោះទៅ រកសកម្មភាពអភិវឌ្ឍន៍។ ដោយអនុវត្តការស្ទង់មតិថ្នាក់ជាតិមួយទៅលើវិស័យពិការភាព

→ អង្គការជនពិការ គួរតែត្រូវបានដាក់បញ្ចូលទៅក្នុងការងារត្រួតពិនិត្យ និងតាមដាន ការចាត់អាទិភាព និងក្នុងគំនិតផ្តួចផ្តើមកសាងសមត្ថភាព

(បញ្ហា ១)- អប់រំ

ជាឧទាហរណ៍បន្ថែមអំពីការប្រឈមវិស័យអប់រំដែលលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៏ជាតិ សព្វថ្ងៃបានប៉ាន់ស្មានថា រហូតដល់ឆ្នាំ២០១០ ការចុះឈ្មោះកុមារទាំងអស់ឱ្យចូលរៀននៅកំរិតបឋមសិក្សា នឹង អាចប្រព្រឹត្តទៅបាន ហេតុដូចនេះ**គោលដៅអភិវឌ្ឍន៏សហស្សវត្សរ៍ក៏អាចសម្រេចបានផងដែរ**។ ទោះបីជាយ៉ាងនេះក្តី **យោងតាមព័ត៌មានដែល**

**ទទួលបានពីអង្គការដែលដំណាងនិងធ្វើការដើម្បីជនពិការបានឱ្យដឹងថាមានកុមារពិការជាច្រើនមិនបានទទួលនូវអត្ថប្រយោជន៍ដែលបង្កលក្ខណៈងាយស្រួលដល់ការចុះឈ្មោះចូលរៀននិងការអប់រំនោះឡើយ**។ ប្រសិនបើមិន មានការវាស់ស្ទង់ឱ្យបានច្បាស់លាស់ពីការចុះឈ្មោះ និងការវិវឌ្ឍក្នុងការអប់រំដល់កុមារពិការយើងព្រួយបារម្ភថា**គោលដៅសហស្សវត្សរ៍នេះ នឹងមិនអាចសម្រេចបាន**។ យើងអាចសន្និដ្ឋានបានថា បញ្ហាប្រឈម ចំបង១ជាច្រើនទៀត មាននៅក្នុងវិស័យផ្សេង១ ហើយដែលអាចជះឥទ្ធិពលអវិជ្ជមានដល់ដំណើរការ ដើម្បីសម្រេច នូវគោលដៅអភិវឌ្ឍន៍ សហស្សវត្សរ៍ ដែលគ្រោងនឹងកាត់បន្ថយភាពក្រីក្រឱ្យបានពាក់កណ្តាល នៅត្រឹមឆ្នាំ២០១៥ ។

**អនុសាសន៍(ខ) ដើម្បី**ដាក់បញ្ចូលទៅក្នុង **ផយអជ** ថ្មី —យុទ្ធសាស្រ្ត និងសកម្មភាពសំខាន់ៗ ទិសដៅ និងក្រុមគោលដៅ

- → ដាក់បញ្ចូលកឋាខ័ណ្ឌមួយនៅក្នុងជំពូកមួយនៃ **ផយអជ** ស្តីពីវឌ្ឍនភាពដែលមានកន្លងមក និងស្ថានភាពបច្ចុប្បន្ន ដោយសំដៅដល់ការអប់រំ ដែលបានលើកឡើងពីគោលនយោបាយអប់រំសម្រាប់កុមារពិការ ដែលបានអនុម័ត (ខែមីនា ឆ្នាំ២០០៨)
- → ដោយនិយាយនៅក្នុងជំពូកនៃផែនការ **ផយអជ** ស្តីពី "យុទ្ធសាស្រ្ត និងសកម្មភាពសំខាន់ៗ" ការអនុវត្តផែនការមេ នៃគោលនយោបាយអប់រំកុមារពិការរបស់ក្រសួងអប់រំ យុវជន និងកីឡា និងគូសបញ្ជាក់ថា:
  - o ដើម្បីវាស់ស្ទង់ពីកម្រិតចុះឈ្មោះចូលរៀន ការប្រមូលទិន្នន័យកុមារអត់បានចូលរៀន វឌ្ឍនភាព និងភាពជោគជ័យនៃការអប់រំកុមារពិការ
  - o ដើម្បីដាក់បញ្ចូលសកម្មភាពជាអាទិភាពជាក់លាក់មួយចំនួន ដូចជាការគាំទ្រដល់រាល់គំនិតផ្តួចផ្តើមលើកកម្ពស់ការចុះឈ្មោះចូលរៀន និងគុណភាពនៃការអប់រំមូលដ្ឋាន អនុវិទ្យាល័យ និង វិទ្យាល័យនៃកុមារពិការ និងយុវជនពិការ។
  - o អភិវឌ្ឍន៍នូវសូចនាករពិការភាព សំរាប់គោលនយោបាយវិស័យអប់រំ និងផែនការគាំទ្រវិស័យអប់រំ ឱ្យគ្រប ដណ្តប់យ៉ាងហោចណាស់ ៥០% នៃថ្នាក់បឋមសិក្សា ដើម្បីអនុវត្តន៏នូវគោលនយោបាយ អប់រំសំរាប់កុមារពិការ និងផែនការមេ ។

**(បញ្ហា គ) អភិបាលកិច្ច វិមជ្ឈការ និងវិសហមជ្ឈការ**

ឯកភាពចំពោះការគាំទ្ររបស់រាជរដ្ឋាភិបាល ចំពោះការអភិវឌ្ឍន៏មូលដ្ឋានដោយមានការចូលរួម ក្នុងផែនការ **ផយអជ** (២០០៦-២០០៩) សំរាប់ការផ្តល់សេវាវិមជ្ឈការ និងវិសហមជ្ឈការ ដែលមានការកើនឡើងនៅថ្នាក់ឃុំ និងសហគមន៍ (៤.១៦ ទំព័រ៣៧ និង៤.១៧)។ យើងកត់សំគាល់ឃើញថា សេវាទាក់ទងនឹងពិការភាព និងជនពិការ គឺមិនត្រូវបានគេ បង្ហាញ នៅក្នុងផ្នែកនេះ នៅក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៏ជាតិទេ។ ចំនួនជនពិការភាគច្រើន រស់នៅជនបទ (៩% នៃប្រជាជនជនបទទាំងអស់ បើប្រៀបធៀបទៅនឹងអត្រាជាតិសរុប ៤%) យោងតាមការស្ទង់មតិសេដ្ឋកិច្ច និងសង្គមកម្ពុជា ឆ្នាំ២០០៤។

**(អនុសាសន៍ គ) សម្រាប់ការដាក់បញ្ចូលសកម្មភាពពិការភាពទៅក្នុង "យុទ្ធសាស្ត្រ និងសកម្មភាពសំខាន់ៗ" ទិសដៅ និងក្រុមគោលដៅនៃផែនការ ផយអជ**

- → ដាក់បញ្ចូលទិសដៅច្បាស់លាស់ ដើម្បីគាំទ្រការផ្សព្វផ្សាយបញ្ហាពិការភាព និងពង្រីកបញ្ហាពិការភាពបន្ថែមទៀត ទៅក្នុងកម្មវិធីជាតិ ១០ឆ្នាំ សំរាប់អភិវឌ្ឍលទ្ធិប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ (ចំនុច ៤.១៨ នៃ **ផយអជ**)។
- → ដាក់បញ្ចូលនូវកម្មវិធីស្តារលទ្ធភាពពលកម្មតាមសហគមន៍ និងច្បាប់ជនពិការ ជាផ្នែកមួយនៃការផ្តល់សេវានៅកំរិតថ្នាក់ឃុំ និងពង្រីកកម្មវិធីទៅគ្រប់ខេត្ត។
- → លើកកម្ពស់ចំណេះដឹងពីទិសដៅ និងវិធីសាស្ត្រស្តារលទ្ធភាពពលកម្មតាមសហគមន៍ ក្នុងផ្នែក (៤.១៧ នៃ **ផយអជ**) សំរាប់ការចាត់អាទិភាពពីតម្រូវការនៅថ្នាក់ឃុំ។
- → គាំទ្រឱ្យមានការបង្កើតនូវគោលនយោបាយ ស្តីពីការបញ្ជ្រាបពិការភាព និងការលើកកម្ពស់ចំណេះដឹងពីសិទ្ធិពិការភាព ក្នុងសកម្មភាពការងាររបស់ក្រសួងមហាផ្ទៃ និងសកម្មភាពទាក់ទងនឹងការកសាងសមត្ថភាព ពាក់ព័ន្ធនឹងដំណើរការកំណែទម្រង់រដ្ឋបាល។

**បញ្ហា (ឃ) ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម**

យើងកត់សំគាល់ឃើញថា **ផយអជ** បានបង្ហាញពីតំរូវការចាំបាច់របស់ជនពិការនៅក្នុងផ្នែក ៤.៨៣ ដូចគ្នាដែរនឹងអ្នកដែលគួរតែមានឈ្មោះទទួលបានមូលនិធិសោធន។ ទោះបីជាយ៉ាងនេះក៏ដោយ ការគូសបញ្ជាក់បន្ថែមទៀត ចាំបាច់ត្រូវធ្វើបច្ចុប្បន្នកម្ម។ កថាខ័ណ្ឌដែលបង្ហាញពីតម្រូវការសម្រាប់ការដាក់បញ្ចូល គឺផ្អែកទៅលើការសន្មត់ ដែលជនពិការទាំងអស់ គួរតែត្រូវបានពិចារណាចំពោះផែនការមូលនិធិសោធន។ ទោះជាយ៉ាងណាក៏ដោយ ជនពិការភាគច្រើនអាចចូលរួមចំណែកក្នុងដំណើរការសេដ្ឋកិច្ច និងការអភិវឌ្ឍនៃប្រទេសកម្ពុជា ប្រសិនបើប្រព័ន្ធសុវត្ថិភាពសង្គម និងវិធានការណ៍ផ្សេងៗធានាសន្តិសុខបានចំពោះសិទ្ធិទទួលសេវាសេដ្ឋកិច្ច និងសង្គម រួមទាំងសេវាទាក់ទងនឹងពិការភាព។

**(អនុសាសន៍ ឃ): សម្រាប់ការដាក់បញ្ចូលពិការភាពទៅក្នុង "យុទ្ធសាស្ត្រ និងសកម្មភាពសំខាន់ៗ" ទិសដៅ និងក្រុមគោលដៅ សម្រាប់ផែនការប្រព័ន្ធសុវត្ថិភាពសង្គម**

- → បញ្ចូលនូវកថាខ័ណ្ឌសំរាប់ប្រព័ន្ធសុវត្ថិភាពសង្គម ដើម្បីគាំទ្រការដាក់បញ្ចូលឡើងវិញ ឬដាក់បញ្ចូលជនពិការទៅក្នុងដំណើរការសេដ្ឋកិច្ច-សង្គមនៅក្នុងប្រទេសកម្ពុជា ដោយគាំទ្រចំពោះការដាក់បញ្ចូលឡើងវិញក្នុងសកម្មភាព ផលិតភាពសេដ្ឋកិច្ច ចំពោះការដាក់បញ្ចូលផែនការមូលនិធិសោធន។
- → ជំរុញការស្តារលទ្ធភាពលកម្មភាពតាមសហគមន៍ និងដាក់បញ្ចូលពិការភាពទៅក្នុងសេវាដែលមានស្រាប់ (សុខភាព និងការអភិវឌ្ឍន៍សេដ្ឋកិច្ច) ចំពោះការដាក់បញ្ចូលផែនការមូលនិធិសោធន។
- → នៅក្នុងការអភិវឌ្ឍន៍មូលនិធិសមធមិសុខភាព និងកម្មវិធីជាតិអត្តសញ្ញាណកម្មគ្រួសារក្រីក្រ បានពិនិត្យមើលចំពោះបទពិសោធន៍ជីវិតប្រចាំថ្ងៃ ទាក់ទងនឹងស្ថានភាពពិការភាពផ្អែកវេជ្ជសាស្ត្រ ដែលជនពិការ និងគ្រួសារ

របស់ពួកគេជួបប្រទះ (រាងកាយ ញាណ ផ្លូវចិត្ត និងភាពខ្សោយបញ្ញា) ដោយរួមបញ្ចូលវគ្គបណ្តុះបណ្តាលស្តីពីពិការភាព ចំពោះរចនាសម្ព័ន្ធពាក់ព័ន្ធនឹងការប៉ាន់ប្រមាណពីការផ្តល់ប័ណ្ណក្រីក្រ និងការផ្តល់រង្វាន់ ជាមូលនិធិសមធមិសុខភាព។

→ ដាក់បញ្ចូលជនពិការ និងគ្រួសាររបស់ពួកគេ ឱ្យទទួលបានសិទ្ធិស្មើភាពគ្នាក្នុងការទទួលបានមូលនិធិសមធមិសុខភាព និងប្រព័ន្ធសុវត្ថិភាពសង្គម

**<u>បញ្ហា (ង)- ការត្រួតពិនិត្យតាមដាន</u>**

ភាពមើលមិនឃើញពីបញ្ហាពិការភាពនៅក្នុងសូចនាករតាមដានរួម ដែលជាឧបករណ៍វាស់ស្ទង់ពីភាពរីក ចំរើនរបស់សកម្មភាព ក៏អាចរារាំងដល់ការអនុវត្ត និងការយល់ដឹងពីភាពជោគជ័យនៃការកាត់បន្ថយភាពក្រីក្រក្នុង និងសកម្មភាពជោគជ័យក្នុងការកាត់បន្ថយភាពក្រីក្រចំណោមជនពិការផងដែរ។ ប្រសិនបើគ្មានការវាស់វែងនោះ សកម្មភាពបច្ចុប្បន្ននឹងមិនអាចធ្វើការកែ តម្រូវឡើងវិញ ក្នុងវិធីមួយដែលប្រកប ដោយព័ត៌មានពេញលេញជាក់ស្តែង និងដោយមានការចូលរួមសហការនោះទេ។ កង្វះខាតទិន្នន័យពីពិការភាពនាពេលបច្ចុប្បន្ន ក៏អាចបង្កើតឱ្យមានការលំបាកក្នុងការធ្វើផែនការយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ផងដែរ។

**<u>អនុសាសន៍ (ង) -សម្រាប់ដាក់បញ្ចូលសកម្មភាពដើម្បីលើកកម្ពស់ការដាក់បញ្ចូលពិការភាពពីការត្រួតពិនិត្យលើគ្រប់វិស័យ</u>**

→ ស្វែងយល់ពីបទពិសោធន៍ជោគជ័យក្នុងការបញ្ជ្រាបយេនឌ័រ នៅក្នុងការងារអភិវឌ្ឍន៍ប្រទេសកម្ពុជា ដើម្បីជាមធ្យោបាយនាំផ្លូវទៅរកការផ្លាស់ប្តូរនៃការអនុវត្ត។

→ ដាក់បញ្ចូលជនពិការនៅក្នុងការត្រួតពិនិត្យសកម្មភាពកាត់បន្ថយភាពក្រីក្រ និងការផ្តល់ថវិកា និងធនធានមនុស្សសមស្របចំពោះវិស័យពិការភាព នៅក្នុងក្រសួងគោលដៅនីមួយៗ គួរតែត្រូវបានធ្វើឡើងផ្អែកលើភាគរយជនពិការក្នុងប្រទេសកម្ពុជា ដោយប្រើប្រាស់ទូរលេខថ្មីពី ជំរឿនឆ្នាំ២០០៨ ដែលជាជំរឿន លើកដំបូងមានរាប់បញ្ចូលជនពិការ។ ឧទាហរណ៍ ការណាត់ជួបជាមួយអ្នកទទួលខុសត្រូវផ្ទាល់លើពិការភាព ឬនាយកដ្ឋានផែនការក្នុងកំរិតមួយដ៏មានប្រសិទ្ធិភាពនៅតាមបណ្តាលក្រសួង ដូចជា (ក្រសួងសុខាភិបាល អប់រំ ការងារ អភិវឌ្ឍន៍ជនបទ មហាផ្ទៃ ក្រុមប្រឹក្សារដ្ឋមន្ត្រី) អាចលើកតម្កើង ការដាក់បញ្ចូលពិការភាពទៅក្នុងការត្រួតពិនិត្យ និងការគាំទ្រដល់គណកម្មាធិការសម្របសម្រួលពិការភាពជាតិ។

→ ពិនិត្យឡើងវិញ និងកែសំរួលនូវនិយមន័យពិការភាពបច្ចុប្បន្ន និងប្រមូលស្ថិតិជនពិការស្របទៅនឹងអនុសាសន៍អនុសញ្ញាអង្គការសហប្រជាជាតិ និងអនុសាសន៍ អង្គការសហប្រជាជាតិ ដើម្បីសេដ្ឋកិច្ច និងសង្គម សំរាប់អាស៊ី និងប៉ាស៊ីភិច ដោយបែងចែកនូវភាពខុសគ្នារវាងមូលហេតុនៃ ពិការភាព/បញ្ហាមុខងារ និងមូលហេតុនៃឧបសគ្គរបស់ពិការភាព ក្នុងការចូលរួមសង្គម។

## ៩. ព័ត៏មានសម្រាប់ទាក់ទង

សម្រាប់ព័ត៌មានបន្ថែម ស្តីពីបញ្ហាដែលបានលើកឡើងក្នុងឯកសារនេះ សូមទំនាក់ទំនង:

**អង្គការជនពិការកម្ពុជា (CDPO):** លោក **នី ញូរ** មន្ត្រីគំរោងបញ្ជ្រាបពិការភាពទៅក្នុងគោលនយោបាយកម្ពុជា

ទូរស័ព្ទ: (៨៥៥-១២) ៧១៥ ៤០៥ និង អ៊ីមែល: mpo@cdpo.org

**ក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC):** លោក **ចន សំផាស់** នាយរង

ទូរស័ព្ទ: ៨៥៥ (១២) ៧០២ ២៧៩ និងអ៊ីម៉ែល: samphors@dac.org.kh

**អង្គការជនពិការអន្តរជាតិ (HIF):** លោក **អ៊ុច សុភា** មន្ត្រីគំរោង

ទូរស័ព្ទ: ៨៥៥ (១១) ៩៧៥ ៨៦៧ និងអ៊ីម៉ែល: pm-prsp@hicambodia.org

**អ្នកចូលរួមរៀបចំសេចក្តីថ្លែងការនេះរួមមាន:**

| | | | |
|---|---|---|---|
| ប្រអប់ "**យេនឌ័រ**" | : | អង្គការបេសកម្មអភិវឌ្ឍន៍ជនពិការកម្ពុជា (CDMD) | លោក សេត វាសនា |
| ប្រអប់ "**ច្បាប់**" | : | អង្គការជនពិការកម្ពុជា (CDPO) | លោក អ៊ាំង ចាន់ដារ៉ា |
| | : | អង្គការកម្ពុជាត្រាស្ត (CT) | លោក John Honney |
| ប្រអប់ "**អប់រំបញ្ចូលគ្នា**" | : | ក្រុមប្រឹក្សាសកម្មភាពពិការ (DAC) | លោក Sarah Jago |
| | : | ទីប្រឹក្សាការអប់រំបញ្ចូលគ្នា | លោកស្រីវេជ្ជបណ្ឌិត Maya Kalyanpur |
| | : | អង្គការមូលនិធិកុមារពិការ | លោក គង់ វិចិត្រា |
| ពិការភាព និង"**ការងារ**" | : | មជ្ឈមណ្ឌលជាតិនៃជនពិការ (NCDP) | លោក អ៊ាន និល |
| ពិការភាព និង"**គ្រាប់មីន**" | : | ក្រុមប្រឹក្សាសកម្មភាពពិការ (DAC) | លោកស្រី មាស ម៉ៅ |
| ប្រអប់ "**សុខភាព**" | : | ក្រុមប្រឹក្សាសកម្មភាពពិការ (DAC) | លោក អ៊ុង សម្បត្តិ |
| អ្នកកែសម្រួលសេចក្តីថ្លែងការណ៍ | : | អង្គការជនពិការអន្តរជាតិ (HIF) | លោកស្រី អ៊ុយរីកេ ឡាស់ |

## ប្រអប់បន្ថែម

**បញ្ហាគន្លឹះ១នៃការដាក់បញ្ចូលពិការនៅក្នុងការអប់រំ**

**សមិទ្ធិផលសម្រេចបាន**

ក្រសួងអប់រំ យុវជន និងកីឡា បានចាត់វិធានការណ៍លើកកម្ពស់ដល់ការអប់រំបញ្ចូលគ្នា សម្រាប់កុមារ ពិការ ដោយអាគារសិក្សាដែលស្ថាបនាថ្មី បានដាក់បញ្ចូលនូវ **"ការសង់ជំរាល"** ទៅក្នុងគំរូប្លង់។ កុមារពិការ បច្ចុប្បន្នត្រូវបានចងក្រងទុកនៅក្នុងបញ្ជីចុះឈ្មោះសិស្ស ហើយទិន្នន័យនេះ នឹងត្រូវយកទៅដាក់បញ្ចូលនៅ ក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ ចាប់ពីឆ្នាំ២០០៩តទៅ ។

គោលនយោបាយអប់រំសម្រាប់កុមារពិការ ត្រូវបានអនុម័តនៅខែមីនា ឆ្នាំ២០០៨ និង ផែនការមេ សំរាប់អនុវត្តន៍

គោលយោបាយត្រូវបានបង្កើត និង ឯកភាព (២០០៩) ។

មានសៀវភៅបណ្តុះបណ្តាលគ្រូបង្រៀនថ្មីពីរស្តីពី សម្រាប់គ្រូការអប់រំក្នុងសេវា ការអប់រំបញ្ចូលគ្នាសម្រាប់កុមារពិការ ត្រូវបានផលិតឡើង នាយកដ្ឋានបណ្តុះបណ្តាលគ្រូ និងការិយាល័យអប់រំពិសេស ក្នុងឆ្នាំ ២០០៩ ។

**អនុសាសន៍: ត្រូវដាក់បញ្ចូលទៅក្នុងផ្នែកអប់រំនៅក្នុងផែនការ ផយអជថ្មី (២០០៩-២០១៣)**

អនុវត្តន៍នូវគោលនយោបាយអប់រំកុមារពិការ និងផែនការមេ សំរាប់អនុវត្តន៍គ្រប់ផ្នែកនៃសកម្មភាពអប់រំ ដូចខាងក្រោមនេះ ការអនុវត្តន៍ល្អ សំរាប់ផលប្រយោជន៍កុមារពិការ និង យុវជន៨០ % នៅឆ្នាំ ២០១៣ ។

ធានាថា អាគារសិក្សាថ្មីទាំងអស់ បង្កលក្ខណៈងាយស្រួល ដូចជាជំរាល និងបង្គន់ស្របតាមស្តង់ដាតាមបែបសាកលវិទ្យាល័យ

ធានាថា សិស្សដែលបានចូលរៀន ទទួលបានឧបករណ៏ជំនួយសម្រាប់ការសិក្សារបស់ពួកគេ

គួសបញ្ជាក់ឱ្យបានច្បាស់លាស់ពីសិទ្ធិរបស់ជនពិការក្នុងការបំរើការងារជាគ្រូបង្រៀន ឆ្នាំ ២០០៩

ផ្សព្វផ្សាយ សៀវភៅបណ្តុះបណ្តាលគ្រូបង្រៀនថ្មី និងរៀបចំវគ្គបណ្តុះបណ្តាលដល់គ្រូបង្រៀនទាំងអស់ បច្ចេកទេសទាក់ទងនឹងភាពខ្សោយដូចជា ពីភាសាសញ្ញា អក្សរស្ទាប និងភាពខ្សោយខាងបញ្ញា ឆ្នាំ ២០១៣

ផ្តល់និងបណ្តុះបណ្តាលគ្រូបង្រៀនអោយប្រើប្រាស់គោលការណ៏ណែនាំបែបសាមញ្ញដើម្បីកំណត់អត្តសញ្ញាណកុមារពិការ ដើម្បីធ្វើឱ្យប្រសើរឡើងដល់ប្រព័ន្ធស្ថិតិចូលរៀនរបស់សិស្សពិការ

ផែនការយុទ្ធសាស្រ្តអប់រំ គួរតែមានរួមបញ្ចូលចំនុចដៅ/សូចនាករជាក់លាក់ណាមួយ ដែលទាក់ទងនឹងការអប់រំកុមារពិការ នៅ ឆ្នាំ ២០១៣

ក្រសួងអប់រំយុវជននិងកីឡា បង្កើននូវសមត្ថភាព ដល់ការិយាល័យអប់រំពិសេស អោយទទួលខុសត្រូវលើការអប់រំបញ្ចូលគ្នា ដើម្បីធ្វើការទំនាក់ទំងគ្នាជាមួយក្រសួងអប់រំយុវជននិង កីឡា មិនគួរធ្វើការតែក្នុងនាយកដ្ឋានអប់រំមឋមតែប៉ុណ្ណោះទេ ។

**បញ្ហាគន្លឹះ១នៃការដាក់បញ្ចូលពិការនៅក្នុងអភិបាលកិច្ច/ច្បាប់**

**សមិទ្ធិផលសម្រេចបាន**

រាជរដ្ឋាភិបាលកម្ពុជា បានចុះហត្ថលេខាលើអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិជនពិការ និងពិធីសារ បន្ថែម (CRPD & OP) នៅ ខែតុលា ឆ្នាំ២០០៧

ក្នុងឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជា បានអនុម័ត ច្បាប់ស្តីពីការការពារ និងលើកកម្ពស់ សិទ្ធិជនពិការ (PPRPD)

ច្បាប់អប់រំក្នុងស្រុក ដែលចែងពិការដាក់បញ្ចូលកុមារពិការ ត្រូវបានអនុម័តកាលពីឆ្នាំ២០០៧

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានយល់ស្របចំពោះការមិនរើសអើងជនពិការ ក្នុងការជ្រើសរើសបុគ្គលិកមន្ត្រីរាជការ ដោយធ្វើការពិនិត្យមើលឡើងវិញ នូវការប្រើប្រាស់នៃច្បាប់សហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល ជំពូកទី២ មាត្រា១១ និង ៥។

**អនុសាសន៍**

រាជរដ្ឋាភិបាលកម្ពុជា ដែលបានផ្តួចផ្តើមចុះហត្ថលេខាទទួលស្គាល់អនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិជនពិការ គួរបន្តធ្វើការឆ្ពោះទៅរកការផ្តល់សច្ចាប័នដល់អនុសញ្ញាអន្តរជាតិទាំងពីរ (CRPD & OP) នេះ

រាជរដ្ឋាភិបាលត្រូវបានលើកទឹកចិត្ត ក្នុងការជំរុញកិច្ចការសំរាប់អនុវត្តន៍ច្បាប់អប់រំ និង ច្បាប់ស្តីពី ការការពារ និងលើកកម្ពស់សិទ្ធិជនពិការ

ទាក់ទងនឹងច្បាប់ពិការភាពអន្តរជាតិ និងក្នុងស្រុកដែលរំពឹងថានឹងកើតមាន ហើយនឹងក្លាយទៅជាផ្នែកមួយនៃប្រព័ន្ធច្បាប់របស់កម្ពុជា រាជរដ្ឋាភិបាលគួរតែៈ

- ត្រួតពិនិត្យមើលឡើងវិញពីភាពស្រដៀងគ្នារវាងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ និង ច្បាប់ការការពារ និងលើកកម្ពស់សិទ្ធិជនពិការ ព្រមទាំងច្បាប់ក្នុងស្រុកដែលពាក់ព័ន្ធផ្សេងៗទៀត និង
- សម្របសម្រួលធ្វើការផ្សព្វផ្សាយព័ត៌មានដល់ជនពិការទាក់ទងនឹងសិទ្ធិរបស់ពួកគេ ដែលមានចែងនៅក្នុងអនុសញ្ញាអង្គកាសហប្រជាជាតិស្តីពីសិទ្ធិជនពិការ (CRPD) និងច្បាប់ការពារ និងលើកកម្ពស់សិទ្ធិជនពិការ (PPRPD) ដល់ប្រជាជនទូទៅ និងរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធអន្តរជាតិ តាមរយៈយុទ្ធនាការផ្សព្វផ្សាយជាក់លាក់ ។

**បញ្ហាគន្លឹះ៦នៃការដាក់បញ្ចូលពិការនៅក្នុងសុខាភិបាល និងវិស័យស្តារ**

**<u>សមិទ្ធិផលសម្រេចបាន</u>**

កិច្ចព្រមព្រៀងរួមរវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការមិនមែនរដ្ឋាភិបាល ចំនួន៥ ដើម្បីទទួលខុសត្រូវមជ្ឈមណ្ឌលស្តារថ្នាក់ខេត្ត ត្រូវបានចុះហត្ថលេខា ឆ្នាំ ២០០៨ ដោយត្រូវប្រគល់ជូនជាផ្លូវការដល់ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាវិញនៅត្រឹមឆ្នាំ២០១១

សេចក្តីណែនាំពីការស្តារកាយសម្បទា និងវេជ្ជសាស្ត្រ ត្រូវបានធ្វើឡើងគ្រប់មន្ទីរពេទ្យខេត្ត តាមរយៈកម្មវិធីអប់រំចល័ត ដែលរៀបចំឡើងដោយ នាយកដ្ឋានការពារវេជ្ជសាស្ត្រ នៃក្រសួងសុខាភិបាល

**<u>អនុសាសន៍</u>**

ក្រសួងសុខាភិបាល គួរតែអនុវត្តន៍នូវការត្រួតពិនិត្យនូវឧបសគ្គដែលរាំងស្ទះដល់ជនពិការ នៅពេលព្យាយាមដើម្បីទទួលនូវសេវាសុខភាព រួមទាំងដាក់បញ្ចូលបញ្ហាពិការភាពទៅក្នុងផែនការយុទ្ធសាស្ត្ររបស់ខ្លួន សំរាប់ជនពិការទទួលបាននូវសេវាសុខភាពស្មើភាពគ្នា និង ទទួលបាននូវមូលនិធិសមធម៌សុខភាព ។

រាជរដ្ឋាភិបាល គួរតែចាត់តាំងក្រសួងបង្គោលណាមួយ ដើម្បីបង្កើតយន្តការនៃការសម្របសម្រួលសម្រាប់ វិស័យស្តារកាយសម្បទា និងសុខាភិបាល

ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពនូវអនុស្សរណៈយោគយល់គ្នា (MoU) នៅក្នុងវិស័យស្តារសកម្មភាពដើម្បីនិរន្តរភាពមួយចំនួន (ធនធានមនុស្ស ហិរញ្ញវត្ថុ ...) ដែលពាក់ព័ន្ធជាមួយនឹងបទពិសោធន៍ជោគជ័យ នៅក្នុងវិស័យសុខាភិបាល គួរតែយកមកអនុវត្ត

អនុវត្តគោលនយោបាយបង្កលក្ខណៈងាយស្រួលផ្នែករូបវន្ត ដល់គ្រប់វេចនាសម្ព័ន្ធសុខាភិបាលក្នុងប្រទេស

ការបង្កើតប្រព័ន្ធអប់រំផ្នែកសុខាភិបាលទាំងឯកជន និងរដ្ឋ ត្រូវតែមានដាក់បញ្ចូលពិការភាពទៅក្នុងកម្មវិធី សិក្សារបស់ពួកគេ នៅឆ្នាំ ២០១៣

**បញ្ហាគន្លឹះ៧នៃការដាក់បញ្ចូលពិការនៅក្នុងមុខរបរ/ការងារ**

**សមិទ្ធិផលសម្រេចបាន**

មូលនិធិសន្តិសុខសង្គម ត្រូវបានបង្កើតឡើងដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ហើយសមាគមអតីតយុទ្ធជន ត្រូវបានបើកជាផ្លូវការនៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០៧

ក្រសួងកិច្ចការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានប្រកាស់លើកដំបូងតែងតាំងជនពិការដើម្បីបំពេញការងារជាបុគ្គលិករបស់ខ្លួន នៅខែមីនា ឆ្នាំ២០០៨

ក្រសួងសង្គមកិច្ច អតីតយុវជន និង យុវនីតិសម្បទា អនុម័តនូវចរាចរណ៍ណែនាំ នូវការបង្កើនស្ថានភាពរស់នៅតាមរយៈបណ្តុះបណ្តាលវិជ្ជាជីវៈ សំរាប់ជនពិការនៅឆ្នាំ ២០០៨ ។

**អនុសាសន៍**

ច្បាប់ការងារ គួរតែគួសបញ្ជាក់អំពីជនពិការឱ្យបានច្បាស់ជាងនេះ នៅក្នុងជំពូកមួយចំនួនដើម្បីលើកកម្ពស់និងការពារពួកគេនៅកន្លែងធ្វើការ

ដកចេញនូវការរើសអើងប្រឆាំងនិង ជនពិការនូវក្នុងវិស័យការងារ ដូចបានបង្ហាញនូវជំពូកទី៧នៃច្បាប់ជនពិការ ។

ក្រសួងការងារនឹងដាក់បញ្ចូលជនពិការទៅវិជ្ជាជីវៈ និងបណ្តុះបណ្តាលបច្ចេកទេស និងចងជាបណ្តាញ បណ្តុះបណ្តាល ដែលនឹងបង្ហាញនូវក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

ក្រសួងការងារ និង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា អនុវត្តន៍នូវបង្កើត អនុក្រឹតលើចំនួននៃការអភិវឌ្ឍន៍ ដែលបានបង្ហាញនូវច្បាប់ជនពិការជំពូកទី ៧

រាជរដ្ឋាភិបាល គួរតែផ្តល់ជារង្វាន់ដល់អង្គការ ឬក្រុមហ៊ុនណាដែលបានជ្រើសរើសបុគ្គលិកមកបំពេញការងាររបស់ខ្លួនជាជនពិការ

ក្រសួង និងបណ្តាអាជ្ញាធរ ទទួលបានការលើកទឹកចិត្តដើម្បីអនុវត្តតាមគំរូរបស់ក្រសួងការបរទេស ព្រមទាំងជំរុញឱ្យមានការជ្រើសរើសបុគ្គលិកជាជនពិការ និងអនុម័តនូវគោលនយោបាយផ្សេងៗ ដើម្បីទប់ស្កាត់រាល់ការរើសអើងនៅទីកន្លែងធ្វើការ និងក្នុងដំណើរការជ្រើសរើសបុគ្គលិក

រាជរដ្ឋាភិបាល គួរតែបង្កើតចំនួនថវិកានៅក្នុងកញ្ចប់ថវិការបស់ខ្លួនសម្រាប់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ និង កំណត់ឱ្យបានច្បាស់នូវចំនួនថវិកាសមស្របណាមួយ សម្រាប់ប្រើប្រាស់ក្នុងការងារដាក់បញ្ចូលជនពិការ

រាជរដ្ឋាភិបាល គួរតែលើកទឹកចិត្ត និងជំរុញឱ្យគ្រប់អាគារសាធារណទាំងអស់ ត្រូវតែបង្កលក្ខណៈងាយស្រួលដល់ជនពិការ

បញ្ហាគន្លឹះ១នៃការដាក់បញ្ចូលពិការទៅក្នុងយេនឌ័រ

**សមិទ្ធិផលសម្រេចបាន**

គោលនយោបាយយេនឌ័រ ត្រូវបានបង្កើតឡើងដោយក្រសួងកិច្ចការនារី នៅខែមេសា ឆ្នាំ២០០៨ ហើយ គោលនយោបាយនេះ ត្រូវបានបញ្ជ្រាបចូលទៅក្នុងគោលនយោបាយ និងប្រព័ន្ធច្បាប់ផ្សេងៗទៀងផងដែរ

វេទិកាមួយចំនួន ត្រូវបានបង្កើតឡើងសម្រាប់ស្ត្រីពិការ នៅថ្នាក់ឃុំ

**អនុសាសន៍**

រាជរដ្ឋាភិបាល គួរតែបញ្ជ្រាប ឬដាក់បញ្ចូលស្ត្រីពិការទៅក្នុងការងាររបស់ក្រសួងកិច្ចការនារី និងបង្កើត នាយកដ្ឋានដែលត្រូវទទួលខុសត្រូវចំពោះស្ត្រីពិការ

ក្រសួងកិច្ចការនារី គួរតែបង្កើតកញ្ចប់មូនិធិណាមួយសម្រាប់អង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការដើម្បី លើកកម្ពស់ចំណេះដឹងអំពីយេនឌ័រដល់ស្ត្រីពិការ

រាជរដ្ឋាភិបាល គួរតែពង្រឹងច្បាប់ គោលនយោបាយ និងឯកសារច្បាប់ផ្សេងៗដែលមានស្រាប់ ដោយរួម បញ្ចូលទាំងបញ្ហារបស់ស្ត្រីពិការផងដែរ

បញ្ហាគន្លឹះ១នៃការដាក់បញ្ចូលពិការទៅក្នុងសកម្មភាពមីន និងសង្គ្រោះជនរងគ្រោះ

**សមិទ្ធិផលសម្រេចបាន**

**សេចក្តីព្រាងផែនការសកម្មភាពជាតិសម្រាប់ជនពិការ រួមជាមួយជនរងគ្រោះដោយសារគ្រាប់មីន និង សំណល់ជាតិផ្ទុះសល់ពីសង្គ្រាម** ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៨-២០០៩

ចំនួនគ្រាប់មីន ធ្លាក់ចុះយ៉ាងគំហុក ដោយសារការដោះមីុន និងការអប់រំពីការគ្រោះថ្នាក់គ្រាប់មីុន ដោយ៨ ភ្នាក់ងារកំពុងបន្តដោះគ្រាប់មីន

ការបង្កា និងសង្គ្រោះ មានភាពប្រសើរជាងមុន តាមរយៈការបង្កើតសេចក្តីព្រៀងគោលនយោបាយ ការថែរទាំរបួសមុនមន្ទីរពេទ្យ និងនៅក្នុងមន្ទីរពេទ្យ កម្មវិធីជំនួយសង្គ្រោះបឋម ដែលកំពុងអនុវត្តន៏ដោយ ក្រសួងសុខាភិបាល កាកបាទក្រហមកម្ពុជា និងអង្គការមិន មែនរដ្ឋាភិបាលមួយចំនួនទៀត និងកម្មវិធី ស្តារលទ្ធភាពពលកម្មតាមសហគមន៏ ដែលបាន នឹងកំពុងដំណើរការនៅក្នុងខេត្តចំនួន១៩

**អនុសាសន៍**

ក្រសួងសុខាភិបាល គួរអនុម័តសេចក្តីព្រាងគោលនយោបាយ ការថែទាំរបួសមុនមន្ទីរពេទ្យ និងនៅក្នុងមន្ទីរពេទ្យ ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន

រាជរដ្ឋាភិបាល គួរតែលើកទឹកចិត្តក្រសួងសុខាភិបាល ឱ្យពង្រីកកម្មវិធីជំនួយសង្គ្រោះបឋម និង កម្មវិធីជាតិ នៃស្តារលទ្ធភាពតាមសហគមន៏ របស់ខ្លួនឱ្យបាន ទូទាំងប្រទេស (រួមបញ្ចូលជនពិការផងដែរ)

រាជរដ្ឋាភិបាល គួរតែពន្លឿនការបញ្ចប់ និងអនុម័តទៅលើសេចក្តីព្រាងផែនការសកម្មភាពជាតិសម្រាប់ជនពិការ **រួមជាមួយជនរងគ្រោះដោយសារគ្រាប់មីន និងសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម** នៅឆ្នាំ ២០០៩

រាជរដ្ឋាភិបាល គួរតែលើកម្ពស់គុណភាពប្រព័ន្ធគាំពារវេជ្ជសាស្ត្រ នៅក្នុង ២៤ ខេត្ត និងនិងបង្កើតសេវាព្យាបាលខួរឆ្អឹងខ្នង នៅមណ្ឌលស្តារថ្នាក់ខេត្តទាំង១១កន្លែង

រាជរដ្ឋាភិបាល គួរប្រើប្រាស់មូលនិធិសមធមិឱ្យបានទូលំទូលាយជាងនេះ ហើយត្រូវរាប់បញ្ចូលជនពិការជាអ្នកទទួលផលពីមូនិធិនេះផងដែរ

រាជរដ្ឋាភិបាល គួរតែលើកកម្ពស់ការកសាងសមត្ថភាពសម្រាប់មន្ត្រីរដ្ឋាភិបាលពាក់ព័ន្ធ ដើម្បីឱ្យពួកគេអាចមានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្តល់សេវាកម្មប្រកបដោយគុណភាព

រាជរដ្ឋាភិបាល គួរតែលើកទឹកចិត្តភ្នាក់ងារដោះមីន ក្នុងការពង្រីកសេវាកម្មរបស់ខ្លួន ដើម្បីកាត់បន្ថយនូវគ្រោះថ្នាក់នាំទៅរកភាពពិការផ្សេងៗ